# ព្រះរាជក្រឹត្យ

នស/រកត/០៤១២/៣១៧

## ស្ដីពី

## ការរៀបចំនិងការប្រព្រឹត្តទៅ

## នៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច

មកដល់ក្រសួង ស.យ.ក
ថ្ងៃទី 10 ខែ 04 ឆ្នាំ 2013
ម៉ោង.......នាទី ចុះលេខ 1351

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

មកដល់ នាយកដ្ឋានអប់រំកុមារតូច
ថ្ងៃ11 ខែ04 ឆ្នាំ2013 ម៉ោង...
ចុះបញ្ជីលេខ 158

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៣

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# គ្រាស់បន្ទាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១:**

ព្រះរាជក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច ដែលសរសេរជាអក្សរកាត់ថា **គ.ជ.គ.ក.** ដើម្បីជាយន្តការអនុវត្តច្បាប់ស្តីពីការអប់រំនិងគោលនយោបាយជាតិស្តីពីការគាំពារនិងការអភិវឌ្ឍកុមារតូច។

## ជំពូកទី២

## សមាសភាពរបស់គ.ជ.គ.ក.

**មាត្រា ២:**

**គ.ជ.គ.ក.**មានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| - នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | | ប្រធានកិត្តិយស |
| - រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងកិច្ចការនារី | ១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល | ១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ១ រូប | អនុប្រធានប្រចាំការ |
| - អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងផែនការ | ១ រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ រូប | សមាជិក។ |

សមាសភាពលេខាធិការដ្ឋានរបស់**គ.ជ.គ.ក.** ត្រូវតែងតាំងដោយអនុក្រឹត្យ។

# ជំពូកទី៣

# តួនាទីនិងភារកិច្ចរបស់គ.ជ.គ.ក.

**មាត្រា ៣:**

**គ.ជ.គ.ក.**មានតួនាទីនិងភារកិច្ចដូចតទៅៈ

- ជំរុញក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធនានា ដើម្បីអនុវត្តតួនាទី ភារកិច្ច ដែលមានចែងក្នុងគោលនយោបាយជាតិស្តីពីការគាំពារនិងការអភិវឌ្ឍកុមារតូច ឲ្យមានប្រសិទ្ធភាព
- ជំរុញនិងសម្របសម្រួលដល់គ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធ រៀបចំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យ ដើម្បីធានាបាននូវការអនុវត្តគោលនយោបាយជាតិស្តីពីការគាំពារនិងការអភិវឌ្ឍកុមារតូច
- ជំរុញនិងសម្របសម្រួលការអនុវត្តគោលនយោបាយជាតិស្តីពីការគាំពារនិងការអភិវឌ្ឍកុមារតូចនៅថ្នាក់ក្រោមជាតិ
- សហការជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់
- អនុម័តនិងផ្សព្វផ្សាយគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍកុមារតូចដល់ក្រសួង ស្ថាប័ន អង្គការជាតិនិងអន្តរជាតិ និងដៃគូអភិវឌ្ឍពាក់ព័ន្ធទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ
- រៀបចំក្របខ័ណ្ឌច្បាប់សម្រាប់អនុវត្តកម្មវិធីគាំពារនិងអភិវឌ្ឍកុមារតូច
- បង្កើតយន្តការស្រាវជ្រាវដើម្បីកំណត់អត្តសញ្ញាណ ស្វែងរក និងពិនិត្យមើលទាន់ពេលវេលាសម្រាប់កុមារតូចដែលមានតម្រូវការពិសេសនិងពិការភាព
- រៀបចំយន្តការគាំទ្រសេវារដ្ឋ សេវាសហគមន៍ សេវាឯកជន តាមផ្ទះនិងតាមខ្នងផ្ទះ ក្នុងការផ្តល់សេវាគាំពារនិងអភិវឌ្ឍកុមារតូច ដោយយកចិត្តទុកដាក់ចំពោះកុមារដែលរស់នៅក្នុងតំបន់ជួបការលំបាក កុមារជនជាតិដើមភាគតិច និងកុមារបាត់បង់ឱកាស
- ពិនិត្យនិងកែលម្អគោលនយោបាយជាតិស្តីពីការគាំពារនិងការអភិវឌ្ឍកុមារតូច
- កៀរគរធនធានសម្រាប់គាំទ្រការអនុវត្តការគាំពារនិងការអភិវឌ្ឍកុមារតូច
- ពិនិត្យតាមដាននិងវាយតម្លៃលើការអនុវត្តគ្រប់កម្មវិធីគាំពារនិងអភិវឌ្ឍកុមារតូច
- ធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការគាំពារនិងការអភិវឌ្ឍកុមារតូច ដើម្បីដាក់ជូនរាជរដ្ឋាភិបាល
- ទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់គ.ជ.គ.ក.

**មាត្រា ៤:**

**គ.ជ.គ.ក.**ត្រូវប្រជុំយ៉ាងតិច២(ពីរ)ដងក្នុងមួយឆ្នាំ តាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីចាំបាច់ ប្រធាន**គ.ជ.គ.ក.**អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍឲ្យមកចូលរួមប្រជុំបាន។

**មាត្រា ៥:**

របៀបរបបនៃការប្រជុំរបស់**គ.ជ.គ.ក.** ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់**គ.ជ.គ.ក.**។

**មាត្រា ៦:**

**គ.ជ.គ.ក.**មានសិទ្ធិប្រើត្រារបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីដំណើរការការងាររបស់ខ្លួន។

**មាត្រា ៧:**

**គ.ជ.គ.ក.**មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានទីតាំងនៅក្នុងក្រសួងអប់រំ យុវជន និងកីឡា។

អគ្គលេខាធិការដ្ឋាននៃ**គ.ជ.គ.ក.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ**គ.ជ.គ.ក.** ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ៨:**

**គ.ជ.គ.ក.**អាចទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញជាតិ ឬអ្នកជំនាញអន្តរជាតិមួយចំនួនតាមការចាំបាច់ ដើម្បីជួយការងារ**គ.ជ.គ.ក.** និងអគ្គលេខាធិការដ្ឋាន។

**មាត្រា ៩:**

**គ.ជ.គ.ក.**ត្រូវបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យចាំបាច់មួយចំនួន ដោយមានសមាសភាពដឹកនាំត្រូវជ្រើសរើសពីសមាជិក**គ.ជ.គ.ក.** និងដែលមានមន្ត្រីជំនាញរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ និងដៃគូអភិវឌ្ឍចូលជាសមាជិក។

សមាសភាព តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន**គ.ជ.គ.ក.**។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា ១០.-**

ការចំណាយសម្រាប់ដំណើរការរបស់គ.ជ.គ.ក.ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិ ក្នុងគម្រោងថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា។

គ.ជ.គ.ក.មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១២.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ៤ ខែមេសា ឆ្នាំ២០១៣

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត.០៤១៣.៣៧២

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ៣១៥ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**
**ស៊យ សុខា**